# ដំណាំអំពៅ



ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម
គំរោងឥណទានកម្មវិធី ធនាគារ អភិវឌ្ឍន៍ អាស៊ី
(ADB) លេខ 1445 - CAM (SF)
ឆ្នាំ ២០០៥

# ដំណាំអំពៅ

ម.ព.ឯ.ក AIDOC
Code: 120-001
Date:
Donated by:



## I. ស្ថានភាពទូទៅ

អំពៅជាដំណាំមួយប្រភេទ ដែលប្រជាកសិករយើងស្គាល់ស្ទើរ គ្រប់គ្នាទាំងអស់ ហើយដំណាំនេះក៏បានដាំដុះលើផ្ទៃដីតូចៗ ស្ទើរពាសពេញនៃព្រះរាជាណាចក្រកម្ពុជាយើងដែរ ។

ជាទូទៅប្រជាកសិករតែងនិយមយកអំពៅមកគាបយកទឹកសំរាប់ហូបដូចជាភេសជ្ជៈធម្មតាឬគេនិយមហូបផ្ទាល់តែម្តង ។ សារៈសំខាន់នៃដំណាំនេះក្នុងប្រទេសយើង ក៏ដូចជាក្នុងភិភពលោក គេបានកែច្នៃទឹកអំពៅយកទៅធ្វើជាស្ករសដែលយើង

ត្រូវការចាំបាច់ខានមិនបានជារៀងរាល់ថ្ងៃ ។ ក្រៅពីសារៈសំខាន់សម្រាប់ធ្វើស្ករអំពៅនៅប្រទេសមួយចំនួនគេបានកែច្នៃទឹកអំពៅយកទៅធ្វើជាអាកុល ស្រា និងធ្វើជាចំណីសត្វហើយម្យ៉ាងទៀតកាកអំពៅគេបានយកទៅកែច្នៃធ្វើជាក្រដាស ក្ដារបន្ទះ ។ល។ ចំពោះប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះ ដំណាំអំពៅគឺគេបានកែច្នៃធ្វើស្ករក្នុងសិប្បកម្មតូចៗប៉ុណ្ណោះក្រៅពីនេះគឺប្រជាកសិករ យើងនិយមហូបទឹកអំពៅដូចជាភេសជ្ជៈធម្មតាប៉ុណ្ណោះ ។

## II. តំបន់ដាំដុះ

ជាទូទៅកសិករយើងតែងតែនិយមដាំដុះអំពៅនៅតំបន់តាមដងទន្លេ ដូចជានៅខេត្ត ក្រចេះ កំពង់ចាម កណ្ដាល ព្រៃវែង ក្រៅពីតំបន់តាមដងទន្លេ គេអាចដាំដំណាំនេះនៅតាមតំបន់ដីខ្ពង់រាប ដីកោះ និងតាមជំរាលជើងភ្នំ លើដីក្រហម ឬ ដីខ្មៅ



ដូចជានៅតាម ខេត្តបាត់ដំបង ស្ទឹងត្រែង មណ្ឌលគិរី រតនគិរី ជាដើម ។ល។

## III. បរិស្ថាននៃដំណាំអំពៅ

អំពៅជាដំណាំមួយប្រភេទដែលទាមទារកំដៅខ្លាំងសំរាប់ការលូតលាស់ដងដើមក្នុងរយៈពេលលូតលាស់ដងដើម ស្លឹក ដំណាំ

នេះទាមទារសីតុណ្ហភាពខ្ពស់ជា មធ្យម ២៥ C ទៅ ៣០ C ក្នុងរយះពេល ២៤ ម៉ោងលើកលែងតែដល់ដំណាក់កាលកកើតស្ករគឺ ២ ទៅ ៣ខែ មុនពេលកាប់ ទើប ទាមទារសីតុណ្ហភាពទាបជាមធ្យម ១៨ ទៅ ២២ អង្សាសេ ដើម្បី អាចបង្កើតជាតិស្ករច្រើន ។

ដំណាំនេះក៏ជាដំណាំមួយដែលត្រូវការទឹកច្រើនបង្គួរដែរ ដូច្នេះដើម្បីធានាឱ្យបានផលល្អគឺយើងត្រូវ ស្រោចបានយ៉ាងណាពេលដែលដំណាំស្ថិតក្នុងដំណាក់កាលលូតលាស់ខ្លាំង អាចចំពេលដែលមានភ្លៀងធ្លាក់ច្រើន ហើយផ្អុយទៅវិញ ប្រមាណជា ២ ទៅ ៣

